អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងសម្គាល់សត្វពស់ដែលមានពិស**

**ចិត្តចលភាព៖ បំណិនចលនាតូច៖**

ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងសាច់ដុំដៃនិងសាច់ដុំភ្នែក៖

**វិទ្យាសាស្ត្រ៖ ប្រតិបត្តិនិងសុវត្ថិភាព៖** ការយល់ដឹងពីការប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព៖/

**ការរស់នៅប្រចាំថ្ងៃ៖** ការស្វែងយល់ការសង្កេត៖

**សិក្សាសង្គម៖ គំនូរនិងសកម្មភាពកសាង៖**

ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព៖

**គោលបំណង**

**(ចិត្តចលភាព)៖ បំណិនបម្មទា៖** កំណត់ចំណុចគោលនៃចលនាដៃដោយការទប់លំនឹង និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ។

**(វិទ្យាសាស្ត្រ)៖ វិជ្ជាសម្បទា៖** ប្រាប់បានពីឈ្មោះ វត្ថុឬសត្វដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដូចជា ភ្លើងអគ្គិសនី ថ្នាំសម្លាប់សត្វល្អិត ថ្នាំពេទ្យ ស្លាកសញ្ញាមីន សញ្ញាចរាចរណ៍ វត្ថុមុតស្រួច ទឹកពាង និងទឹកស្រះជាដើម។

**បំណិតសម្បទា៖** ប្រៀបធៀបនិងរៀបរាប់ឈ្មោះសត្វ ចរឹកលក្ខណៈ លក្ខខណ្ឌរស់នៅ វដ្តនៃសត្វ ការប្រៀបធៀបសត្វនិងផលប្រយោជន៍។

**(សិក្សាសង្គម)៖ វិជ្ជាសម្បទា៖** ប្រាប់បានពីរបៀបបត់ រោយ ដេរ ល្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់ ដើម្បីបង្កើតជារូបភាពផ្សេងៗ។

**ចរិយាសម្បទា៖** រហ័សរហួននិងប្រុសប្រយ័ត្នក្នុងការចាប់កាន់ បត់ សូន គូស ហែក កាត់និងផាត់ពណ៌ផ្សេងៗ។

**កម្រិតសិក្សា** ៖ទាប មធ្យមនិង ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសសន្លឹកកិច្ចការ (ទំហំA4: សខ្មៅ / ពណ៌) (ទំហំA5: សខ្មៅ / ពណ៌) ដីតដ្ឋដែលមាន៣ឬ៤ពណ៌

**ការរៀបចំ** ៖ ត្រូវរៀបចំសម្ភារដែលត្រូវលេងឱ្យបានគ្រប់គ្រាន់ជាការស្រេច។

**សេចក្តីណែនាំ** ៖

1. សួរកុមារថាស្គាល់សត្វពស់ដែរឬទេ? កូនៗខ្លាចពស់ដែរឬទេ? តើកូនៗដឹងទេថាពស់អ្វីដែលមានពិសខ្លះ?
2. ពេលបានឃើញសត្វពស់ តើកូនៗធ្វើយ៉ាងមិច?
3. ប្រាប់កុមារថាថ្ងៃនេះពួកយើងនឹងទៅស្គាល់ពស់ដែលមានពិសនៅក្នុងប្រទេសកម្ពុជាទាំងអស់គ្នាផងដែរ។
4. បង្ហាញកាតសត្វទាំងអស់ដែលបានត្រៀមទុក
5. យើងមានក្រដាសមួយទៀតដែលនិយាយពីលម្អិតពីសត្វពស់នីមួយៗ
   អ្នកត្រូវអានពីសេចក្ដីលំអិតរបស់ពស់នីមួយៗទៅកាន់កុមារមុននឹងចាប់ផ្ដើមឱ្យកុមារលេងសូនរូបពស់។
6. នៅពេលដែលអាន និងប្រាប់ពួកគេរួចរាល់ហើយ ចាប់ផ្ដើមឱ្យដីឥដ្ឋទៅកុមារ
   និងឱ្យកុមារទាំងអស់ជ្រើសរើសពស់ណាមួយ និងធ្វើជាសត្វពស់នោះ
   ជាមួយដីឥដ្ឋដែលមានពណ៌ទាំងនោះជាការស្រេច។
7. ល្បែងនេះគ្រាន់តែចង់ឱ្យកុមារបានស្គាល់ប្រភេទសត្វពស់ដែលមានពិស
   និងត្រូវជៀសឱ្យឆ្ងាយពីសត្វទាំងអស់នោះផងដែរ។
8. នៅពេលដែលលេងរួចហើយ ចូរឱ្យកុមារជួយរៀបចំសម្ភារឱ្យមានរបៀបរៀបរយផង។

**ការប្រែប្រួល** ៖

ល្បែងនេះអាចលេងជាប្រភេទបន្លែ ឬប្រភេទសត្វ ឬផ្លែឈើផ្សេងៗជាដើមក៏បានដែរ។ ដើម្បីឱ្យកុមារបានស្គាល់បន្លែ ផ្លែឈើ ឬប្រភេទសត្វផ្សេងផងដែរ។